## Remembering



| | | |
|---|---|---|
| ១ | សម្បត្តិ៖ | [និយាយម្នាក់ឯង] ចុម ឆ្នាំងសាកអាយហ្វូន ទៅណាបាត់ហើយ? ម៉េចអត់ឃើញចឹង? |
| | លីដា៖ | ឆ្នាំងសាកអាយហ្វូនអ៎? ខ្ញុំនៅហ្នឹងយូរហើយតាំងពីព្រឹក ដូចអត់ឃើញផង។ សម្បត្តិឯងភ្លេចយកមោ៉ទេដឹង? |
| | សម្បត្តិ៖ | អត់ទេ ខ្ញុំចាំថាយកមោ៉តាស។ កុំអាល គិតមើលសិន ភ្លេចដៃទុកណាអញ្ចេះ? សាករកមើលក្នុងកាតាបសិន។ |
| | លីដា៖ | ហ៊ើយ! ឃើញហើយ! នៅនេះសោះ ខំតែភ័យ។ |
| | សម្បត្តិ៖ | ចាស់ហើយ ភ្លេចភ្លាំងច្រើន! |
| | | |
| ២ | លីដា៖ | សម្បត្តិ មិញមានឃើញឯកសារខ្ញុំទុកហ្នឹងអេ៎? |
| | សម្បត្តិ៖ | ឃើញលីដាឯងកាន់យកទៅនោះហើយតាសមិញ។ |
| | លីដា៖ | ដំបូងខ្ញុំកាន់ទៅ តែខ្លាចប្រឡាក់ ខ្ញុំក៏យកមោ៉វិញ ហើយគិតថាទុកហ្នឹងម៉ាភ្លែតហ្នឹងអ៎ា។ |
| | សម្បត្តិ៖ | អឹម ... អត់ដឹងទេអីចឹង។ ខ្ញុំទើបតែមោ៉ដែរ។ ... នោះមែន លីដា? |
| | លីដា៖ | ហ្នឹងហើយ! ហាក ម៉េចទៅនៅហ្នុងវិញ? អ៎ូ ... ចាំហើយ! ខ្ញុំទៅកូពីក្រដាស ហើយទុកហ្នុងមួយភ្លែតមិញ។ |
| | សម្បត្តិ៖ | យ៉ាប់ម៉ង។ |

| | |
|---|---|
| សម្បត្តិ / លីដា | male / female Cambodian name |
| ចុម | exclamation expressing (negative) surprise, or when in doubt about sth. |
| ឆ្នាំងសាក | charger (e.g., of a mobile phone) |
| អាយហ្វូន | iPhone |
| ចឹង | colloquial form of អញ្ចឹង or អីចឹង = like this, like that |
| អ៎ | particle used to form a yes/no question, similar to ឬ |
| ខ្ញុំនៅហ្នឹង | = ខ្ញុំនៅទីនេះ |
| ... ទេដឹង? | Maybe ... ?, Couldn't it be that ... ? |
| កុំអាល គិតមើលសិន | Wait (a minute), let me think! |
| ភ្លេចដៃ | to forget where something was put |

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

| | |
|---|---|
| ខំតែភ័យ | I was worried |
| ភ្លេចភ្លាំង | to be forgetful |
| អេ៎ | spoken form of the question or negation particle ទេ |
| អា៎ | spoken form of ណា |
| នោះមែន ? | Isn’t that it? |
| ហាក | exclamation expressing surprise |
| កូពី | to copy |
| យ៉ាប់ម៉ង | You’re really difficult! (not meant seriously) |

## Cultural notes

នៅខ្មែរ នៅពេលឃើញមនុស្សម្នាក់ភ្លេចភ្លាំងច្រើន គេតែងចំអន់លក្ខណៈលេងសើចថា មនុស្សនោះចាស់ហើយ ឬក៏ មនុស្សនោះនិយាយខ្លួនឯងថា ខ្លួនចាស់ហើយ ភ្លេចភ្លាំងច្រើន។ និយាយលេងសើចម្យ៉ាងទៀតគឺ នៅពេលមនុស្សម្នាក់និយាយមុនពេលចេញដំណើរថា “មានភ្លេចអីទេហ្ន៎ ?” គេអាចនិយាយទៅវិញថា “បើភ្លេចម៉េចនឹកឃើញ ?” ។

| | |
|---|---|
| ចំអន់ | to tease, to joke |
| ហ្ន៎ | final particle to soften a statement or request, similar to ណា |
| បើភ្លេចម៉េចនឹកឃើញ ? | If you’ve forgotten [something], how can you remember it now? |

## Additional dialogue

រៀបចំខ្លួនទៅញ៉ាំការ

លីដា៖ កញ្ញា ម៉េចហើយ ? រួចរាល់នៅ ? រៀងយឺតហើយណា។
កញ្ញា៖ ហើយៗ លីដា តស់។ ... អ៊ុះ ភ្លេចសំបុត្រ!
លីដា៖ វិះ កញ្ញាឯង។ ទៅយកម៉ោលឿន! ...
កញ្ញា៖ [និយាយម្នាក់ឯង] ចុម មិញខ្ញុំបិទម៉ាស៊ីនត្រជាក់ហើយនៅហ្ន៎ ?
លីដា៖ ឃើញលីដាឯងបិទហើយតាស។
កញ្ញា៖ អីចឹងអ៎ ? អត់អីអេ៎អីចឹង។ តស់ទៅ។ តែដូចភ្លេចអីគេម្យ៉ាង ...
លីដា៖ កាបូបកញ្ញាឯងទូចអីចឹង ដាក់ទូរស័ព្ទចូលដែរ ?
កញ្ញា៖ អ៊ូ នឹកឃើញហើយ ភ្លេចទូរស័ព្ទហ្នឹងអា៎!

| | |
|---|---|
| ញ៉ាំការ | wedding, wedding ceremony or party |
| សំបុត្រ ( ចំណងដៃ ) | envelope in which money is put as a wedding gift |
| វិះ កញ្ញាឯង។ | That was close, កញ្ញា! |

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.